# ថ្នាំបង្ការរោគ HPV (រោគប៉ាពិលឡូម៉ាវីរុស នៅក្នុងមនុស្ស)

**Gardasil®**

## អ្វីដែលលោកអ្នកត្រូវដឹង

មានសេចក្តីថ្លែងព័ត៌មានថ្នាំបង្ការរោគ ជាច្រើន ជាភាសាអេស្ប៉ាញ៉ុល និងជាភាសាផ្សេងៗទៀត ។ សូមមើលនៅ www.immunize.org/vis ។

## 1 តើរោគ HPV ជាអ្វីទៅ?

**រោគប៉ាពិលឡូម៉ាវីរុសនៅក្នុងអង្គជាតមនុស្ស** ឬភាសាអង់គ្លេសហៅថា **Genital human papillomavirus (HPV)** គឺជាមេរោគវីរុសម្យ៉ាង ជាទូទៅបំផុត ដែលឆ្លងតាមរយៈការរួមដំណេក នៅក្នុងសហរដ្ឋអាមេរិក ។ មានបុរស និងស្ត្រីជាងពាក់កណ្តាល ដែលសកម្មក្នុងការរួមដំណេក ត្រូវបានឆ្លងរោគ HPV នៅពេលណាមួយក្នុងជីវិតរបស់គេ ។

នៅពេលបច្ចុប្បន្ននេះ មានប្រជាជនអាមេរិកាំងប្រហែល 20 លាននាក់បានឆ្លងរោគ ហើយប្រហែល 6 លាននាក់ទៀត ក៏នឹងបានឆ្លងរោគជារៀងរាល់ឆ្នាំ ។ តាមធម្មតា រោគ HPV គឺបានឆ្លងតាមរយៈការរួមដំណេក ។

ភាគច្រើននៃរោគ HPV មិនបណ្តាលឲ្យមានរោគសញ្ញាអ្វីឡើយ ហើយអាចជាសះស្បើយដោយឯកឯងដែរ ។ ក៏ប៉ុន្តែរោគ HPV អាចបណ្តាលឲ្យកើតរោគមហារីកកស្បូនក្នុងស្ត្រីភេទ ។ **រោគមហារីក-កស្បូន** គឺជារោគមហារីកទី 2 ដែលបណ្តាលឲ្យស្ត្រីស្លាប់ នៅជុំវិញពិភពលោក ។ នៅក្នុងសហរដ្ឋអាមេរិក មានស្ត្រីប្រហែល 10,000 នាក់ បានកើតរោគមហារីក-កស្បូន ជារៀងរាល់ឆ្នាំ ហើយប្រហែល 4,000 នាក់ទៀត នឹងត្រូវស្លាប់ដោយសាររោគនេះ ។

រោគ HPV ក៏ជាប់ទាក់ទងនឹងមហារីកដែលពុំសូវទូទៅជាច្រើនទៀតដែរ ដូចជារោគមហារីកយោនី និងទ្វារយោនី ក្នុងចំណោមស្ត្រី ព្រមទាំងរោគមហារីកប្រភេទផ្សេងៗទៀត ក្នុងចំណោមបុរស និងស្ត្រី ។ វាក៏អាចបណ្តាលឲ្យមានឫសក្នុងអង្គជាត(ប្រដាប់បន្តពូជ) និងមានឫសក្នុងបំពង់ក ផងដែរ ។

សព្វថ្ងៃនេះពុំមានថ្នាំព្យាបាលរោគ HPV ឲ្យជាស្រឡះទេ ប៉ុន្តែអាចព្យាបាលបញ្ហាខ្លះៗរបស់វាបាន ។

## 2 ថ្នាំបង្ការរោគ HPV – តើហេតុអ្វីបានជាត្រូវទទួលថ្នាំបង្ការរោគ?

ថ្នាំបង្ការរោគ HPV គឺជាសារៈសំខាន់ ពីព្រោះ**វាអាចការពារករណីភាគច្រើន នៃរោគមហារីក-កស្បូន** ក្នុងស្ត្រីភេទ បើសិនជាគេបានចាក់ថ្នាំនោះមុនពេលបានឆ្លងមេរោគវីរុស ។

វិធីការពារអំពីថ្នាំបង្ការរោគ HPV បានរំពឹងថាមានប្រសិទ្ធិភាពរយៈពេលយូរ ។ ក៏ប៉ុន្តែ ការទទួលថ្នាំបង្ការរោគ គឺមិនជំនួសការត្រួតពិនិត្យរោគមហារីក-កស្បូនឡើយ ។ ស្ត្រីគួរតែទទួលការធ្វើតេស្តរោគមហារីកស្បូន(ប៉ាបតេស្ត) យ៉ាងទៀងទាត់ជាបន្តទៀត ។

ថ្នាំបង្ការរោគដែលអ្នកកំពុងតែទទួល គឺជាថ្នាំម្យ៉ាង ក្នុងបណ្តា**ថ្នាំបង្ការរោគពីរប្រភេទ ដែលអាចបានផ្តល់ឲ្យដើម្បីការពាររោគ HPV ។** ថ្នាំនេះអាចផ្តល់ទៅឲ្យទាំងបុរស និងស្ត្រីបាន ។ ជាបន្ថែមលើវិធីការពារនូវរោគមហារីក-កស្បូន វាក៏អាចការពារ**រោគមហារីកយោនី និងទ្វារយោនី** ក្នុងស្ត្រីភេទបានដែរ ព្រមទាំង**រោគឫសក្នុងអង្គជាត(ប្រដាប់បន្តពូជ)** ក្នុងបុរសនិងស្ត្រីផងដែរ ។

ថ្នាំបង្ការរោគប្រភេទផ្សេងៗទៀត ត្រូវបានផ្តល់ឲ្យតែស្ត្រីប៉ុណ្ណោះ ហើយក៏សំរាប់ការពាររោគមហារីក-កស្បូន តែប៉ុណ្ណោះ ។

## 3 តើអ្នកណាខ្លះ គួរតែទទួលថ្នាំបង្ការរោគ HPV និងនៅពេលវេលាណា?

### ស្ត្រី : *ការចាក់ថ្នាំបង្ការរោគ ជាប្រក្រតី*

- ថ្នាំបង្ការរោគ HPV ត្រូវបានឲ្យយោបល់សំរាប់ក្មេងស្រី **អាយុ 11 ឆ្នាំ ឬ 12 ឆ្នាំ ។** ថ្នាំនេះអាចនឹងបានផ្តល់ទៅឲ្យក្មេងស្រី ចាប់ផ្តើមនៅអាយុ 9 ឆ្នាំ ។

**តើហេតុអ្វីបានជាថ្នាំបង្ការរោគ HPV ត្រូវបានផ្តល់ទៅឲ្យក្មេងស្រីនៅអាយុនេះ?**

វាគឺជាសារៈសំខាន់សំរាប់ក្មេងស្រី ដើម្បីទទួលថ្នាំបង្ការរោគ HPV នៅ**មុនពេល**គេរួមដំណេកជាលើកដំបូង - ប្រយោជន៍កុំឲ្យគេបានឆ្លងរោគប៉ាពិលឡូម៉ាវីរុសក្នុងមនុស្ស ។

កាលណាក្មេងស្រី ឬស្ត្រី បានឆ្លងមេរោគវីរុសនេះហើយ ថ្នាំបង្ការរោគនឹងពុំមានប្រសិទ្ធិភាពល្អ ឬនឹងគ្មានប្រសិទ្ធិភាពសោះឡើយ ។

### ស្ត្រី : *ការចាក់ថ្នាំបង្ការរោគ ជាបង្គ្រប់*

- ថ្នាំបង្ការរោគនេះ ក៏ត្រូវបានឲ្យយោបល់សំរាប់ក្មេងស្រី និងស្ត្រី ពីអាយុ **13 ឆ្នាំ រហូតដល់ 26 ឆ្នាំ** ដែលពុំបានទទួលថ្នាំ 3 ដូស្ស(កំរិតថ្នាំ) កាលពីគេមានវ័យក្មេងនៅឡើយ ។

### បុរស

បុរស**អាយុពី 9 ឆ្នាំ រហូតដល់ 26 ឆ្នាំ** អាចនឹងទទួលថ្នាំបង្ការរោគ HPV ដើម្បីការពាររោគឫសក្នុងអង្គជាតបាន ។ វាជាការល្អប្រពៃ ដែលត្រូវចាក់ថ្នាំបង្ការរោគមុនពេលរួមដំណេកជាលើកដំបូង ដូចគ្នានឹងស្ត្រីដែរ ។

### ថ្នាំបង្ការរោគ HPV ត្រូវបានផ្តល់ឲ្យ 3 ដូស្ស ជាហូរហែ

| | |
|---|---|
| ដូស្សទី 1 | ឥឡូវនេះ |
| ដូស្សទី 2 | ពី 1 ទៅ 2 ខែ បន្ទាប់ពីដូស្សទី 1 |
| ដូស្សទី 3 | 6 ខែ បន្ទាប់ពីដូស្សទី 1 |

ដូស្សថែមទៀត (បន្ថែម) គឺមិនបានឲ្យយោបល់ទេ ។

ថ្នាំបង្ការរោគ HPV អាចនឹងបានផ្តល់ឲ្យនៅពេលព្រមគ្នា ដូចនឹងថ្នាំបង្ការរោគផ្សេងទៀតដែរ ។

## 4 មនុស្សខ្លះមិនគួរគប្បីទទួលថ្នាំបង្ការរោគ HPV ទេ ឬគួរតែរង់ចាំ

- ជនណាម្នាក់ ធ្លាប់មានប្រតិកម្មដែលយាយីអាយុជីវិត ចំពោះគ្រឿងផ្សំណាមួយនៃថ្នាំបង្ការរោគ HPV ឬកំរិតថ្នាំបង្ការរោគ HPV ពីមុនៗ មិនគួរគប្បីទទួលថ្នាំបង្ការរោគនេះឡើយ ។ ត្រូវប្រាប់គ្រូពេទ្យរបស់អ្នក បើសិនមនុស្សដែលត្រូវបានចាក់ថ្នាំបង្ការរោគ មានប្រតិកម្មធ្ងន់ធ្ងរអ្វីមួយ រួមទាំងមានប្រតិកម្មចំពោះមេដំបែ ។

- ថ្នាំបង្ការរោគ HPV គឺមិនបានឲ្យយោបល់សំរាប់**ស្ត្រីមានផ្ទៃពោះ**ទេ ។ តែជាយ៉ាងណាមិញ ការទទួលថ្នាំបង្ការរោគ HPV នៅពេលមានផ្ទៃពោះ គឺមិនមែនជាមូលហេតុដើម្បីពិចារណាពីការពន្លូតកូនឡើយ ។ ស្ត្រីដែលបំបៅដោះកូន អាចនឹងទទួលថ្នាំបង្ការរោគនេះបាន ។

  ស្ត្រីណាម្នាក់ ដែលដឹងថាខ្លួនមានផ្ទៃពោះ នៅពេលគាត់បានទទួលថ្នាំបង្ការរោគ HPV នេះ យើងសូមដាស់តឿនឲ្យទាក់ទងទៅ **កន្លែងចុះបញ្ជីការមានផ្ទៃពោះ HPV** របស់អ្នកផលិត តាមលេខ 800-986-8999 ។ យ៉ាងនេះនឹងជួយយើងឲ្យរៀនអំពីរបៀបស្ត្រីមានផ្ទៃពោះ សមប្រកបនឹងថ្នាំបង្ការរោគជាយ៉ាងណា ។

- មនុស្សដែលមានជំងឺគ្រុនស្រាល នៅពេលបំរុងចាក់ថ្នាំបង្ការរោគ HPV ក៏នៅតែអាចចាក់ថ្នាំបង្ការរោគបានដែរ ។ មនុស្សដែលមាន**ជំងឺគ្រុនមធ្យម ឬធ្ងន់ធ្ងរ** គួរតែរង់ចាំរហូតទាល់តែគេបានគ្រាន់បើសិន ។

## 5 តើមានគ្រោះថ្នាក់អ្វីខ្លះ បណ្តាលមកពីថ្នាំបង្ការរោគនេះ?

គេបានប្រើថ្នាំបង្ការរោគ HPV នេះ នៅក្នុងសហរដ្ឋអាមេរិក និងជុំវិញពិភពលោក ជាច្រើនឆ្នាំមកហើយ ព្រមទាំងមានសុវត្ថិភាពណាស់ដែរ ។

តែជាយ៉ាងណាមិញ ថ្នាំប្រភេទអ្វីមួយ សុទ្ធតែអាចបណ្តាលឲ្យមានបញ្ហាធ្ងន់ធ្ងរ ដូចជា មានប្រតិកម្មខ្លាំង ជាដើម ។ ភាពគ្រោះថ្នាក់នៃថ្នាំបង្ការរោគណាមួយ ដែលបណ្តាលឲ្យ គ្រោះថ្នាក់ធ្ងន់ធ្ងរ ឬស្លាប់ គឺមានតិចតួចពេកណាស់ ។

ប្រតិកម្មដែលយាយីអាយុជីវិត បណ្តាលមកពីថ្នាំបង្ការរោគ គឺកម្រមានណាស់ ។ បើសិនជាវាកើតឡើង វាមានក្នុងពេលពីរបីនាទី ទៅពីរបីម៉ោង បន្ទាប់ពីបានទទួលថ្នាំបង្ការរោគ ។

គេដឹងថាបញ្ហា**គ្រុនស្រាល ទៅមធ្យម** ជាច្រើន អាចកើតឡើងជាមួយនឹងថ្នាំបង្ការរោគ HPV ។ រោគសញ្ញាទាំងនេះពុំត្រាំត្រែងយូរទេ ហើយក៏បាត់វិញដោយឯកឯង ។

- ប្រតិកម្មនៅក្នុងដៃ ត្រង់កន្លែងមុខម្ជុល :
  - ឈឺ (ប្រហែល 8 នាក់ ក្នុងបណ្តា 10 នាក់)
  - ឡើងក្រហម ឬហើម (ប្រហែល 1 នាក់ ក្នុងបណ្តា 4 នាក់)
- គ្រុនក្តៅ :
  - គ្រុនស្រាល (100° F) (ប្រហែល 1 នាក់ ក្នុងបណ្តា 10 នាក់)
  - គ្រុនមធ្យម (102° F) (ប្រហែល 1 នាក់ ក្នុងបណ្តា 65 នាក់)
- បញ្ហាផ្សេងៗទៀត :
  - ឈឺក្បាល (ប្រហែល 1 នាក់ ក្នុងបណ្តា 3 នាក់)
  - ការភាំងស្មារតី ។ ការភាំងមួយស្របក់ និងរោគសញ្ញាជាប់ទាក់ទង (ដូចជាការកន្ត្រាក់ នៅពេលកំរើក) អាចកើតឡើងបន្ទាប់ពីការព្យាបាលអ្វីមួយ រួមទាំងការចាក់ថ្នាំបង្ការរោគ ។ **ការអង្គុយចុះ ឬការតម្រេតខ្លួន ប្រហែល 15 នាទី បន្ទាប់ពីចាក់ថ្នាំរួច អាចជួយការពារការភាំងស្មារតី និងរបួសបណ្តាលមកពីការដួល ។** ត្រូវប្រាប់គ្រូពេទ្យរបស់អ្នក បើសិនជាអ្នកវិលមុខ ឬធេងធោង ឬផ្លាស់ប្តូរការមើលឃើញ ឬក៏ហ៊ឹងត្រចៀក ។

ថ្នាំបង្ការរោគ HPV នឹងត្រូវបន្តឃ្លាំមើលនូវបញ្ហាខុសពីធម្មតា ឬធ្ងន់ធ្ងរ ដូចគ្នានឹងថ្នាំបង្ការរោគទាំងអស់ដែរ ។

## 6 ចុះបើសិនជាមានប្រតិកម្មធ្ងន់ធ្ងរវិញនោះ?

### តើខ្ញុំត្រូវឃ្លាំមើលអ្វីខ្លះ?

ប្រតិកម្មធ្ងន់ធ្ងរ រួមមានការកន្ទួលស្បែក; ការហើមដៃនិងប្រអប់ជើង មុខ ឬបបូរមាត់; និងការពិបាកដកដង្ហើម ។

### តើខ្ញុំត្រូវធ្វើយ៉ាងណា?

- ទូរស័ព្ទទៅគ្រូពេទ្យ ឬយកមនុស្សនោះទៅជួបគ្រូពេទ្យជាបន្ទាន់ ។
- ប្រាប់គ្រូពេទ្យ អំពីអ្វីដែលបានកើតឡើង បានកើតឡើងនៅថ្ងៃខែឆ្នាំណា និងវេលាម៉ោងប៉ុន្មាន ហើយបានទទួលថ្នាំបង្ការរោគពីពេលណា ។
- ស្នើគ្រូពេទ្យរបស់អ្នក ឲ្យរាយការណ៍អំពីប្រតិកម្មដោយបំពេញក្រដាសប្រព័ន្ធរបាយការណ៍ព្រឹត្តិការណ៍ប្រតិកម្មថ្នាំបង្ការរោគ (Vaccine Adverse Event Reporting System - VAERS) ។ ឬអ្នកអាចបំពេញសេចក្តីរាយការណ៍នេះ តាមវ៉ិបសៃត៍របស់ VAERS នៅឯ www.vaers.hhs.gov ឬដោយទូរស័ព្ទទៅលេខ 1-800-822-7967 ។

*VAERS មិនផ្តល់ឱវាទផ្នែកសុខភាពឡើយ ។*

## 7 កម្មវិធីជាតិ ផ្នែកសំណងគ្រោះថ្នាក់ បណ្តាលមកពីថ្នាំបង្ការរោគ

កម្មវិធីជាតិផ្នែកសំណងគ្រោះថ្នាក់បណ្តាលមកពីថ្នាំបង្ការរោគ (Vaccine Injury Compensation Program - VICP) បានបង្កើតឡើងនៅឆ្នាំ 1986 ។

បុគ្គលណាដែលជឿថាគេប្រហែលជាមានគ្រោះថ្នាក់ ដោយសារថ្នាំបង្ការរោគ អាចប្តឹងសំណងជាមួយនឹង VICP ដោយទូរស័ព្ទទៅលេខ 1-800-338-2382 ឬមើលវ៉ិបសៃត៍របស់គេនៅឯ www.hrsa.gov/vaccinecompensation ។

## 8 តើខ្ញុំធ្វើយ៉ាងណា ឲ្យបានយល់ដឹងបន្ថែមទៀត?

- សាកសួរគ្រូពេទ្យរបស់អ្នក ។ គេអាចផ្តល់ពត៌មានដែលមានភ្ជាប់ជាមួយប្រអប់ថ្នាំ ឬផ្តល់យោបល់អំពីប្រភពព័ត៌មានផ្សេងៗទៀត ។
- សូមទូរស័ព្ទទៅក្រសួងសុខាភិបាលប្រចាំតំបន់ ឬក្រសួងសុខាភិបាលរដ្ឋ ។
- សូមទាក់ទងទៅមណ្ឌលសំរាប់ទប់ស្កាត់ និងបង្ការជំងឺ (Centers for Disease Control and Prevention - CDC) :
  - សូមទូរស័ព្ទទៅលេខ **1-800-232-4636 (1-800-CDC-INFO)** ឬ
  - សូមមើលវ៉ិបសៃត៍របស់ CDC នៅ **www.cdc.gov/std/hpv** និង **www.cdc.gov/vaccines**


DEPARTMENT OF HEALTH AND HUMAN SERVICES
CENTERS FOR DISEASE CONTROL AND PREVENTION

Vaccine Information Statement (Interim)
Human Papillomavirus (HPV) *Gardasil* IMM-866CA – Cambodian (3/30/2010) 42 U.S.C. §300aa-26
Translated by Transcend Translations, Davis, CA www.transcend.net